


វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រឹត្តិបត្រព័ត៌មាន ឆ្នាំ ២០២១

## មាតិកា

១. សមិទ្ធផល នៃការបណ្ដុះបណ្ដាល និង វិក្រឹតការសមត្ថភាពឆ្នាំ ២០២១ ........ ១
២. កម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ២
៣. កម្មវិធីបណ្ដុះបណ្ដាលរយៈពេលខ្លីក្រោមកិច្ចសហការជាមួយក្រសួងស្ថាប័ន ........ ២
៤. វគ្គបណ្ដុះបណ្ដាលតម្រង់ទិសជូនមន្ត្រីរាជការក្របខណ្ឌថ្មីថ្នាក់កណ្ដាលឆ្នាំ ២០១៨-២០២០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ........ ៧
៥. កិច្ចសហការរវាង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដៃគូអភិវឌ្ឍ ........ ៧

## ១. សមិទ្ធផល នៃការបណ្ដុះបណ្ដាល និង វិក្រឹតការសមត្ថភាពឆ្នាំ ២០២១

វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានអនុវត្តយ៉ាងសកម្មលើការងារកសាង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន លើមុខជំនាញចាំបាច់សម្រាប់អនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កម្មវិធីបណ្ដុះ-បណ្ដាល របស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានផ្ដោតជាសំខាន់ លើមុខជំនាញឯកទេសមូលដ្ឋាន និង ជំនាញឯកទេសជាក់លាក់ដែលឆ្លើយតបទៅនឹងតម្រូវការរបស់ក្រសួងស្ថាប័ននីមួយៗ ។ កម្មវិធីបណ្ដុះបណ្ដាល និង វិក្រឹតការសមត្ថភាពរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានផ្ដោតលើមុខជំនាញរួមមាន÷ ថវិកាកម្មវិធី និង អង្គភាពថវិកា, លទ្ធកម្មសាធារណៈ, គណនេយ្យសាធារណៈ, ហិរញ្ញវត្ថុ, សវនកម្ម, ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, និង ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលសុទ្ធតែជាប្រធានបទដ៏សំខាន់ ក្នុងការពង្រឹងពង្រីកសមត្ថភាព និង លើកកម្ពស់ការយល់ដឹងជូនមន្ត្រីរាជការ ។

ក្នុងឆ្នាំ ២០២១ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្ដុះបណ្ដាលជូនមន្ត្រីរាជការគ្រប់មន្ទីរអង្គភាពជំនាញរាជធានី-ខេត្ត បានចំនួន ៣៧ វគ្គ និងមានសិក្ខាកាមសរុបចំនួន ២.៥០៧ នាក់ ក្នុងនោះវគ្គសិក្សាដែលរៀបចំឡើងដោយវិទ្យាស្ថាន សេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានចំនួន ៣៤ វគ្គ មានសិក្ខាកាមសរុប ២.៤៣១ នាក់ និង វគ្គបណ្ដុះបណ្ដាលដែលរៀបចំឡើងក្រោមកិច្ចសហការរៀបចំសម្របសម្រួលជូនក្រសួងស្ថាប័នចំនួន ៣ វគ្គ មានសិក្ខាកាមសរុប ៧៦ នាក់ ។ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រេចបាន វគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីក្នុងប្រទេសសរុបចំនួន ២១ វគ្គ ដែលមានសិក្ខាកាមគោលដៅចូលរួមសរុបចំនួន ១.៦១៩ នាក់, វគ្គបណ្ដុះបណ្ដាលរយៈពេលមធ្យមក្នុងប្រទេសសរុបចំនួន ៦ វគ្គ ដែលមានសិក្ខាកាមគោលដៅចូលរួមសរុបចំនួន ២៦៨ នាក់, វគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិសរុបចំនួន ៧ វគ្គ ដែលមានសិក្ខាកាមគោលដៅចូលរួមសរុបចំនួន ៥៤៤ នាក់, និង វគ្គបណ្ដុះបណ្ដាលក្រោមកិច្ចសហការរៀបចំសម្របសម្រួលជូនក្រសួងស្ថាប័នសរុបចំនួន ៣ វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៧៦ នាក់ ។ វគ្គបណ្ដុះបណ្ដាលខាងលើត្រូវបានរៀបចំឡើងក្នុងទម្រង់ជាវគ្គបណ្ដុះបណ្ដាលពីចម្ងាយ ដោយប្រើប្រាស់ប្រព័ន្ធសិក្សាពីចម្ងាយរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈកម្មវិធី Zoom Video Conference និង Microsoft Team ក្នុងគោលដៅចូលរួម ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ (COVID-19) ដោយគោរពតាមវិធានការរបស់ក្រសួងសុខាភិបាល ។

## ២. កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**
រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

នាព្រឹកថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២១, តាមរយៈប្រព័ន្ធ Zoom Video Conference **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** បានអញ្ជើញបើកវគ្គបណ្តុះបណ្តាលជាស៊េរីស្តីពី“**ជំនាញបច្ចេកទេសលើការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១**” ជូនថ្នាក់ដឹកនាំ និង មន្ត្រីបច្ចេកទេសក្រសួងស្ថាប័នពាក់ព័ន្ធទៅនឹងនីតិវិធី នៃការរៀបចំថវិកា, គណនេយ្យសាធារណៈ, ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, នីតិវិធីអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ក្នុងគោលបំណងពង្រឹងពង្រីកចំណេះដឹង និង សមត្ថភាព ដើម្បីឆ្លើយតបតម្រូវការចាំបាច់ នៃការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ។

ក្រោមការដឹកនាំចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**, ក្នុងឆ្នាំ ២០២១ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលមធ្យមស្តីពី “**ជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**” ដោយសម្រេចបានចំនួន ៦ វគ្គ និង មានសិក្ខាកាមគោលដៅចូលរួមមាន÷ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ, មន្ត្រីគ្រប់គ្រងថវិកា, រជ្ជទេយ្យករបុរេប្រទាន, រជ្ជទេយ្យករបុរេប្រទានរង, រជ្ជទេយ្យករចំណូល, រជ្ជទេយ្យករចំណូលរង, មន្ត្រីទទួលបន្ទុកការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ, មន្ត្រីទទួលបន្ទុកកិច្ចការលទ្ធកម្មសាធារណៈ, និង មន្ត្រីរាជការដែលបំពេញការងារពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន ដែលមានសិក្ខាកាមសរុបចំនួន ២៦៨ នាក់ ។ វគ្គបណ្តុះបណ្តាលរយៈពេលមធ្យមស្តីពី “**ជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**” ត្រូវបានរៀបចំឡើងក្នុងទម្រង់វគ្គបណ្តុះបណ្តាលពីចម្ងាយ ដោយប្រើប្រាស់ប្រព័ន្ធសិក្សាពីចម្ងាយរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ប្រើប្រាស់កម្មវិធី Video Conference (Microsoft Team) ។

---

## ៣. កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី ក្រោមកិច្ចសហការជាមួយក្រសួងស្ថាប័ន

### ៣.១ កម្មវិធីបណ្តុះបណ្តាលដែលរៀបចំឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ





នាព្រឹកថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២១, តាមរយៈប្រព័ន្ធ Zoom Video Conference, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី “**ការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា និង ឯកសារបង្រៀន សម្រាប់វគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២១**” ដែលបានប្រព្រឹត្តទៅក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អិន អែម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** និង មានការចូលរួមពី លោកនាយករង លោក លោកស្រី ប្រធាននាយកដ្ឋាន នៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រូបង្គោលរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ៤៥ នាក់ ។ សិក្ខាសាលាពិគ្រោះយោបល់នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង

ដើម្បីពង្រឹងពង្រីកសមត្ថភាពក្នុងការរៀបចំឯកសារ កម្មវិធី និង វិធីសាស្ត្របង្រៀន លើមុខវិជ្ជាថវិកា, គណនេយ្យសាធារណៈ, លទ្ធកម្មសាធារណៈ, ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ, សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល និង សិល្បៈនៃការប្រាស្រ័យទាក់ទង សម្រាប់គាំទ្រដល់ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី“**ជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២១**” ជូនមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន ។






នាព្រឹកថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០២១ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសហការជាមួយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំពិធីបើកវគ្គបណ្តុះបណ្តាល និង វិក្រឹតការ ស្តីពី “**លទ្ធកម្មសាធារណៈ**” ជូនមន្ត្រីរាជការ នៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានីខេត្តទាំង ២៥ តាមរយៈប្រព័ន្ធ ZOOM Video Conference ។ កម្មវិធីបើកវគ្គបណ្តុះបណ្តាលនេត្រូវបានរៀបចំឡើងក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** អមដោយលោកនាយករង លោក លោកស្រីប្រធាននាយកដ្ឋាន គ្រូបង្គោល គ្រូឧទ្ទេស នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង មន្ត្រីរាការនៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល ៣ថ្ងៃ ពីថ្ងៃទី ៩-១១ ខែ សីហា ឆ្នាំ ២០២១ ។




នាព្រឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២១ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការជាមួយអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំពិធីប្រកាសបើកវគ្គបណ្តុះបណ្តាលស្តីពី “**ការបណ្តុះបណ្តាល គ្រូបង្គោល (Training of Trainers)**” ជូនគ្រូបង្គោលរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រូបង្គោល របស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធ Zoom Video Conference ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានការចូលរួមពីលោក **គង់ វឌ្ឍនៈ អគ្គាធិការរង** នៃអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អមដោយ **ឯកឧត្តមបណ្ឌិត ភេង ឱម** សាស្ត្រាចារ្យវិទ្យាសាស្ត្រអប់រំ និង លោកបណ្ឌិត**ស៊ូ សុធីរ** សាស្ត្រាចារ្យវិទ្យាសាស្ត្រអប់រំនៃរាជបណ្ឌិត្យសភាកម្ពុជា ព្រមទាំងលោកនាយករង

លោក លោកស្រីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និង គ្រូបង្គោលរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រូបង្គោលរបស់អគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ វគ្គបណ្តុះបណ្តាលនេះ មានរយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ១៦-១៨ ខែ សីហា ឆ្នាំ ២០២១ ដោយមានការធ្វើបទឧទ្ទេសនាមដោយ **ឯកឧត្តមបណ្ឌិត គង់ ខៀម** សាស្ត្រាចារ្យវិទ្យាស្ថានអប់រំ និង លោកបណ្ឌិត **ស៊ូ សុធីរ** សាស្ត្រាចារ្យវិទ្យាសាស្ត្រអប់រំ នៃរាជបណ្ឌិត្យសភាកម្ពុជា ។






នាព្រឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២១ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំបើកវគ្គបណ្តុះបណ្តាល និងវិក្រឹតការជាស៊េរីចំនួន ៤ វគ្គស្តីពី "**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" និង "**គណនេយ្យសាធារណៈ**" ជូនមន្ត្រីរាជការទទួលបន្ទុកការងារពាក់ព័ន្ធ របស់មន្ទីរអង្គភាពជំនាញខេត្តព្រៃវែង ខេត្តប៉ៃលិន ខេត្តកែប និង ខេត្តព្រះសីហនុ តាមរយៈប្រព័ន្ធ Zoom Video Conference ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** និង មានការចូលរួមពី ឯកឧត្តម លោកជំទាវ អភិបាលរង នៃគណៈអភិបាលខេត្តព្រៃវែង ខេត្តប៉ៃលិន ខេត្តកែប និង ខេត្តព្រះសីហនុ ព្រមទាំងលោកនាយករង លោក លោកស្រីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ និង មន្ត្រីរាជការ នៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រូបង្គោលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សិក្ខាកាមសរុបប្រមាណ ១០០ នាក់ ។ វគ្គទី១: ស្តីពី "**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១៣-១៥ ខែ កញ្ញា ឆ្នាំ ២០២១ ជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃមន្ទីរអង្គភាពជំនាញ របស់ខេត្តព្រៃវែង សរុបចំនួន ៧៥ នាក់, វគ្គទី២: ស្តីពី "**គណនេយ្យសាធារណៈ**" បានប្រព្រឹត្តទៅពីថ្ងៃទី ១៦-១៧ ខែ កញ្ញា ឆ្នាំ ២០២១ ជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃមន្ទីរអង្គភាពជំនាញ របស់ខេត្តប៉ៃលិន សរុបចំនួន ៧៥ នាក់, វគ្គទី៣: ស្តីពី "**គណនេយ្យសាធារណៈ**" បានប្រព្រឹត្តទៅពីថ្ងៃទី ២២-២៣ ខែ កញ្ញា ឆ្នាំ ២០២១ ជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃមន្ទីរអង្គភាពជំនាញ របស់ខេត្តកែប សរុបចំនួន ៧៥ នាក់, និង វគ្គទី៤: ស្តីពី "**គណនេយ្យសាធារណៈ**" ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ២៩-៣០ ខែ កញ្ញា ឆ្នាំ ២០២១ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃមន្ទីរអង្គភាពជំនាញ របស់ខេត្តព្រះសីហនុ សរុបចំនួន ៧៥ នាក់ ។

នាព្រឹកថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២១ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសហការជាមួយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលជាស៊េរីចំនួន ២ វគ្គ ស្តីពី "**នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**" ជូនមន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនៃមន្ទីរអង្គភាពជំនាញ និង រដ្ឋបាលក្រុង ស្រុក នៃខេត្តស្វាយរៀង និង ខេត្តកែប តាមរយៈប្រព័ន្ធ Zoom Video Conference ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ**







**និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** និង មានការចូលរួមពី ឯកឧត្តមអភិបាលរង នៃគណៈអភិបាលខេត្តស្វាយរៀង និង ខេត្តកែប ឯកឧត្តមអគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងលោកនាយករង លោក លោកស្រីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យ មន្ត្រីរាជការ នៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គ្រូបង្គោល និង គ្រូឧទ្ទេសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង សិក្ខាកាមសរុបប្រមាណ ៩៥ នាក់ ។

វគ្គបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅតាមរយៈប្រព័ន្ធ Zoom Video Conference លើប្រធានបទស្តីពី “**នីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**” ដោយវគ្គទី១: បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២០-២១ ខែ កញ្ញា ឆ្នាំ ២០២១ ជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃមន្ទីរអង្គភាពជំនាញ និង រដ្ឋបាលក្រុង ស្រុក របស់ខេត្តស្វាយរៀង សរុបចំនួន ៧៥ នាក់ និង វគ្គទី២: បានប្រព្រឹត្តទៅពីថ្ងៃទី ២១-២២ ខែ កញ្ញា ឆ្នាំ ២០២១ ជូនថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃមន្ទីរអង្គភាពជំនាញ និង រដ្ឋបាលក្រុង ស្រុក របស់ខេត្តកែប សរុបចំនួន ៧៥ នាក់ ។





នាព្រឹកថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០២១ តាមរយៈប្រព័ន្ធ Zoom Video Conference, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាល និង វិក្រឹតការស្តីពី “**លទ្ធកម្មសាធារណៈ**” ជូនសិក្ខាកាមគោលដៅជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការចំនួន ២២ រូប របស់វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍកសិកម្មកម្ពុជា ។ វគ្គបណ្តុះបណ្តាល និងវិក្រឹតការនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងពង្រីកសមត្ថភាព និង លើកកម្ពស់ការយល់ដឹងជូនមន្ត្រីទទួលបន្ទុកការងារលទ្ធកម្ម សំដៅចូលរួមចំណែកធានាឱ្យបាននូវតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព នៃការអនុវត្តថវិកាជាតិ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមគោលការណ៍បច្ចេកទេស និង អនុលោមតាមលិខិត បទដ្ឋានគតិយុត្តជាធរមាន ។

ពិធីបើកវគ្គនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** និង មានការអញ្ជើញចូលរួមពី **លោក ឡោ ប៊ុណ្ណា នាយកវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍកសិកម្មកម្ពុជា** និង លោកនាយករង លោកលោក ស្រីប្រធាននាយកដ្ឋានជាថ្នាក់ដឹកនាំ នៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍកសិកម្មកម្ពុជា គ្រូឧទ្ទេស និង សិក្ខាកាមសរុបប្រមាណ ៣០ រូប ។

ថ្លែងនៅក្នុងពិធីនោះ ឯកឧត្តមនាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានគូសបញ្ជាក់ថា ការកសាង និង ការអភិវឌ្ឍសមត្ថភាព គឺជាកិច្ចការគន្លឹះមួយ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តែងតែយកចិត្តទុកដាក់ ក្នុងគោលដៅលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ ដែលទទួលមុខងារ តួនាទី ភារកិច្ច ពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របពេលដែលនីតិវិធីបច្ចុប្បន្នកម្មចាំបាច់មួយចំនួន ពាក់ព័ន្ធទៅនឹងការអនុវត្តថវិកាកម្មវិធី និង អង្គភាពថវិកា ត្រូវបានរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្តនិងកំពុងត្រូវបានយកចិត្តទុកដាក់ខ្ពស់ពីគ្រប់ក្រសួងស្ថាប័ន ។







នាព្រឹកថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២១ តាមប្រព័ន្ធ Zoom Video Conference, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលពីចម្ងាយស្តីពី "**នីតិវិធីអនុវត្តថវិកាសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល**" ជូនមន្ត្រីចំនួន ៦០ នាក់ ដែលទទួលមុខងារ ពាក់ព័ន្ធ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់សមត្ថភាព ចំណេះដឹង និង ការយល់ដឹង ប្រកបដោយ គុណភាព និង ស៊ីជម្រៅ ស្របតាមបទដ្ឋានគតិយុត្តថ្មីៗ ពាក់ព័ន្ធការអនុវត្តថវិកា ដោយ ផ្តោតលើប្រធានបទ ដូចជា នីតិវិធីរៀបចំថវិកាតាមប្រព័ន្ធថវិកាថ្មីរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល, ការអនុវត្តថវិកា, នីតិវិធីគ្រប់គ្រងរជ្ជទេយ្យចំណូល រជ្ជទេយ្យបុរេប្រទាននិងកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទានដែលចូលរួមធ្វើបទឧទ្ទេស និង ចែករំលែក ចំណេះដឹង និង បទពិសោធន៍ ដោយគ្រូបង្គោល មកពីអគ្គនាយកដ្ឋានថវិកា និង អគ្គនាយកដ្ឋាន រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

ពិធីបើកវគ្គបណ្តុះបណ្តាលនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានការចូលរួមពី លោកនាយករង លោក លោកស្រីប្រធាននាយកដ្ឋាន ជាថ្នាក់ដឹកនាំ នៃវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គ្រូឧទ្ទេស គ្រូបង្គោល និង សិក្ខាកាមសរុបប្រមាណ ៧០ រូប ។










នាព្រឹកថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០២១តាមរយៈប្រព័ន្ធ Zoom Video Conferencing, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី "**ភាពជាអ្នកដឹកនាំ និង ការគ្រប់គ្រងការផ្លាស់ប្តូរ**" ជូនសិក្ខាកាមគោលដៅ សរុបចំនួន ៣៤ រូប ដែលជាគ្រូបង្គោល និង ថ្នាក់ដឹកនាំ នៃអគ្គាធិការដ្ឋាន និង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ វគ្គបណ្តុះបណ្តាលនេះ មានគោលដៅបង្កើនសមត្ថភាពដល់ថ្នាក់ដឹកនាំ គ្រូបង្គោល និង មន្ត្រីរាជការ ឱ្យបានយល់ដឹងកាន់តែច្បាស់ ទៅលើការពិនិត្យឡើងវិញពីភាពជាអ្នកដឹកនាំ, លក្ខណៈនិងស្ថានភាពជាអ្នកដឹកនាំ, អំណាច និង សីលធម៌ នៃភាពជាអ្នកដឹកនាំ, ភាពជាអ្នកដឹកនាំ ចក្ខុវិស័យ វប្បធម៌ និង គុណតម្លៃ, គ្រប់គ្រងការផ្លាស់ប្តូរ, ជំនាញសំខាន់ៗសម្រាប់ភាពជាអ្នកដឹកនាំ និង ការកសាងនិងដឹកនាំក្រុមប្រកបដោយប្រសិទ្ធភាព ដែលត្រូវ ធ្វើបទឧទ្ទេសដោយគ្រូឧទ្ទេស នៃសាកលវិទ្យាល័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

ពិធីបើកវគ្គបណ្តុះបណ្តាលនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង **ឯកឧត្តម ឆាយ រតនៈ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយ មានការចូលរួមពី លោកនាយករង លោកអគ្គាធិការរង លោក លោកស្រីប្រធាននាយកដ្ឋាន ថ្នាក់ដឹកនាំវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អគ្គាធិការដ្ឋាន គ្រូឧទ្ទេស និង សិក្ខាកាមសរុបប្រមាណ ៥០ រូប ។

## ៤. វគ្គបណ្តុះបណ្តាលតម្រង់ទិស សម្រាប់មន្ត្រីរាជការក្របខណ្ឌថ្មី ឆ្នាំ ២០១៨-២០២០ នៅថ្នាក់កណ្តាល របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ





នាព្រឹកថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០២១, នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, បានរៀបចំពិធីបើក "**វគ្គបណ្តុះបណ្តាលតម្រង់ទិសជូនសិក្ខាកាមជាមន្ត្រីរាជការក្របខណ្ឌថ្មីថ្នាក់កណ្តាល របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ ២០១៨-២០២០**" ចំនួន ៣១៩ នាក់ ដែលអញ្ជើញមកពីមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃរាជធានីខេត្ត និង អង្គភាពថ្នាក់មូលដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យប្រកបដោយប្រសិទ្ធភាព និង ចីរភាព ។ អង្គពិធីនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ពេជ្រ សម្បត្តិ អនុរដ្ឋលេខាធិការ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** អមដោយ ឯកឧត្តមនាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លោកនាយករង និង តំណាងអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលសហការរៀបចំដោយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំដៅលើកកម្ពស់សមត្ថភាពជូនមន្ត្រីរាជការក្របខណ្ឌថ្មី អំពីចំណេះដឹងមូលដ្ឋានសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, រចនាសម្ព័ន្ធដឹកនាំ និង គ្រប់គ្រង និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, កិច្ចការរដ្ឋបាលសាធារណៈ និង ទិដ្ឋភាពសំខាន់ៗ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៅកម្ពុជា ដើម្បីតម្រង់ទិសការអនុវត្តតួនាទីភារកិច្ចជូនក្រសួង ក៏ដូចជាជូនមន្ទីរអង្គភាព ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

នាព្រឹកថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២១ តាមរយៈប្រព័ន្ធ Zoom Video Conference, វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, មានរៀបចំពិធីបើក "**វគ្គបណ្តុះបណ្តាលតម្រង់ទិស ជូនសិក្ខាកាមជាមន្ត្រីរាជការក្របខណ្ឌថ្មីថ្នាក់កណ្តាល របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ ២០១៨-២០២០**" ចំនួន ៥៦៣ នាក់ ។ អង្គពិធីនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ និង ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងគ្រូឧទ្ទេស និង សិក្ខាកាមប្រមាណ ៨០ រូប ។

## ៥. កិច្ចសហការរវាង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ដៃគូអភិវឌ្ឍ

### ៥.១ កិច្ចសហការរវាង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង Civil Service College (CSC) ប្រទេសសិង្ហបុរី

ចាប់ពីឆ្នាំ២០២០ មក វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានបន្តកិច្ចសហការជាមួយ Civil Service College (CSC) របស់ប្រទេសសិង្ហបុរី រៀបចំវគ្គបណ្តុះបណ្តាល រហូតដល់ត្រីមាសទី ៣ ឆ្នាំ ២០២១ ។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងដើម្បីពង្រឹងពង្រីកសមត្ថភាព និង លើកកម្ពស់ការយល់ដឹងរបស់គ្រូបង្គោលអំពីគរុកោសល្យ វិធីសាស្រ្តបង្រៀន និង ជំនាញក្នុងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព តាមរយៈបទពិសោធន៍របស់ Civil Service College (CSC) ប្រទេសសិង្ហបុរី ជាពិសេស ដើម្បីចូលរួមចំណែកគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងឆ្នាំ ២០២១ នេះ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសហការជាមួយ Civil Service College (CSC) របស់ប្រទេសសិង្ហបុរី រៀបចំវគ្គបណ្តុះបណ្តាលជូនគ្រូបង្គោល និង គ្រូឧទ្ទេស ដែលអញ្ជើញមកពីគ្រប់អគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង គ្រូបង្គោលរបស់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ៣ វគ្គ÷ វគ្គបណ្តុះបណ្តាលពីចម្ងាយស្តីពី "**ជំនាញ**

សម្របសម្រួលប្រកបដោយប្រសិទ្ធភាព (Effective Facilitation Skills)" ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១, វគ្គបណ្តុះបណ្តាលពីចម្ងាយស្តីពី "**ការបណ្តុះបណ្តាលគ្រូបង្គោល (TOT Implementation)**" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២១ ដល់ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០២១, និង សិក្ខាសាលាស្តីពី "**បទពិសោធន៍សិង្ហបុរីក្នុងការជំរុញលទ្ធផលនៃការអនុវត្តថវិកា**" ដែលបាន ប្រព្រឹត្តនាថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២១ ។

## ៥.២ កិច្ចសហការរវាង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)




នាព្រឹកថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២១, **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** បានអញ្ជើញបើកវគ្គបណ្តុះបណ្តាលស្តីពី "**ការគ្រប់គ្រងសាច់ប្រាក់**" ជូនសិក្ខាកាមជាថ្នាក់ដឹកនាំមន្ត្រីរាជការចំនួន ១២៥ រូប អញ្ជើញមកពីក្រសួងស្ថាប័ននៃ រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមពីលោក Sailendra Pattanayak **អនុប្រធានផ្នែកកិច្ចការសារពើពន្ធ នៃមូលនិធិរូបិយវត្ថុអន្តរជាតិ** ( Fiscal Affairs Department) តំណាងមូលនិធិរូបិយវត្ថុ (IMF), ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងលោក Alexandros Mourmouras និង លោក Suhas Joshi **ទីប្រឹក្សាជាន់ខ្ពស់រតនាគារនៃមូលនិធិរូបិយវត្ថុអន្តរជាតិ** ។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងចែករំលែក និង ផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធការព្យាករ និង គ្រប់គ្រងសាច់ប្រាក់ ជាឧត្តមានុវត្តអន្តរជាតិ តាមរយៈអ្នកជំនាញជាន់ខ្ពស់ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) ឆ្លើយតបនឹងតម្រូវការ នៃការពង្រឹងពង្រីកចំណេះដឹង និង លើកកម្ពស់ការយល់ដឹង ជូនថ្នាក់ដឹកនាំមន្ត្រីរាជការរបស់ក្រសួងស្ថាប័ន ស្របពេលដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាល ៣ បូក ២ ក្នុងគោលដៅ "**ពង្រឹងប្រសិទ្ធភាព នៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" និង "**បញ្ចប់ការរៀបចំខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម**" ក្នុងដំណាក់កាលទី៤ នៅពេលខាងមុខ ។

## ៥.២ កិច្ចសហការរវាង វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង វិទ្យាស្ថានហិរញ្ញវត្ថុ និង អភិវឌ្ឍអាស៊ី-ប៉ាស៊ីភិច (AFDI)







នាថ្ងៃទី ២៣ - ២៤ ខែ សីហា ឆ្នាំ ២០២១, ថ្ងៃទី ២៩-៣០ ខែ វិច្ឆិកា ឆ្នាំ ២០២១, និង ថ្ងៃទី ២០-២១ ខែ ធ្នូ ឆ្នាំ ២០២១ វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង វិទ្យាស្ថានហិរញ្ញវត្ថុ និង អភិវឌ្ឍអាស៊ី- ប៉ាស៊ីភិច (AFDI) នៃទីក្រុងសៀងហៃ ប្រទេសចិន បានសហការរៀបចំវគ្គបណ្តុះបណ្តាល ពីចម្ងាយចំនួន ៣ វគ្គស្តីពី "**ភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន (PPPs): បទពិសោធន៍ប្រទេសចិន**" ជូនថ្នាក់ដឹកនាំ ថ្នាក់នាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័ន សរុបចំនួន ៥៥ នាក់ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន អេម នាយកវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និង ជាប្រធានក្រុមការងារកសាងសមត្ថភាព របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** និង មានការចូលរួមពីតំណាង AFDI នៃប្រទេសចិន ។

វគ្គបណ្តុះបណ្តាលនេះ មានគោលដៅចូលរួមចំណែក ក្នុងការពង្រឹងពង្រីកសមត្ថភាព លើកកម្ពស់ការយល់ដឹង និង ផ្លាស់ប្តូរបទពិសោធន៍ពាក់ព័ន្ធ សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនមន្ត្រីរាជការកម្ពុជា ពិសេសពាក់ព័ន្ធនឹងការអនុវត្តគម្រោងភាពជាដៃគូរវាងរដ្ឋ និង ឯកជន ។